ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ ២១២

ចុះថ្ងៃទី០៩ខែសីហាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៨៥

ចុះថ្ងៃទី១១ខែឧសភាឆ្នាំ១៩៩៩

នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១_ ឯកឧត្តម ឌិត មុន្ទី ប្រធាន
២_ លោក ប៉ែន ស៊ុន ចៅក្រម
៣_ លោក យុល មួន ចៅក្រមរបាយការណ៍
៤_ លោក ជីវ កេង ចៅក្រម
៥_ លោក ស៊ិន ឌីម ចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី សាន ធារី

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១៧៣ចុះថ្ងៃទី៣០_៤_៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៧៥ ចុះថ្ងៃទី ០៣_១២_៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ស៊ឹម ញ៉ុក ភេទ ប្រុស អាយុ ៤៤ ឆ្នាំជាតិខ្មែរ របររកស៊ី រត់ម៉ូតូឌុប មានទីលំនៅ ក្រុម៣ ភូមិចំការសំរោងទី១ ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។ ឳពុកឈ្មោះ ញាណ ស៊ឹម ( រស់ ) ម្តាយឈ្មោះ តឹក លៀប ( រស់ ) ប្រពន្ធឈ្មោះ ឡុញ យ៉ាន មានកូន ០៦នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ សៀក ចាន់ណារី ភេទស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ របររកស៊ី មុខរបរលក់ដូរ មានទីលំនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្តបាត់_ដំបង ។ ឳពុកឈ្មោះ ហោ ប៊ុន (រ) ម្តាយឈ្មោះជួន តឹមសាត (រ) ប្តីឈ្មោះ ឃិត ប៊ុនរិទ្ធិ មានកូន ០៤នាក់ ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាន

បានឃើញបណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ លោក ស៊ុម ញ៉ិក បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ១៧៣ចុះថ្ងៃទី៣០ ខែមេសាឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២១២ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៨ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១២_១១_៩៥ អ្នកស្រីស្បៀក ចាន់ណារី ប្តឹងសុំឱ្យលោកស៊ុម ញ៉ិក ដកដំណាំចេញពីដីរបស់ខ្លួន និង ឱ្យចេញសងថ្លៃដំណាំខ្លួន និង សុំសិទ្ធិគ្រប់គ្រងដីនោះជាកម្មសិទ្ធិ ដោយសំអាង ហេតុថាខ្លួនបានរស់នៅភូមិចំការសំរោង១ តាំងពីឆ្នាំ១៩៧៩ដោយបានកាប់ឆ្ការដីគ្រប់គ្រងមានទំហំ២១ ,៣ម×២៣ម។ ក្នុងការគ្រប់គ្រងខ្លួនបានធ្វើផ្ទះទំហំ ១០ម×១១ម និងដាំឡូងមីជារបង ចេក សាគូ ល្ហុង ប្រទាល ដើមថ្នាំ។ លុះដល់ឆ្នាំ ១៩៩២ លោក ស៊ុម ញ៉ិក បានយកដំណាំមកដាំចូលលើដីរបស់ខ្លួនប្រវែង៦ម×២១ ,៣ម ដោយ បានកាប់ដំណាំខ្លួនអស់ម្តងហើយ ពេលនោះខ្លួនបានទៅប្តឹងរដ្ឋអំណាច ភូមិ ឃុំ ក៏បានចុះធ្វើអន្តរាគមន៍ដោយយក បង្គោលមកបោះជាព្រំប្រទល់ដើម្បីជៀសវាងទំនាស់ លុះដល់ថ្ងៃទី ០៩_៧_៩៥ ស្រាប់តែ លោក ស៊ុម ញ៉ិក បានមកកាប់បំផ្លាញដំណាំខ្លួនម្តងទៀត ហើយយកចេកមកដាំលើដីរបស់ខ្លួន ទោះជារដ្ឋអំណាចមកហាមឃាត់ក៏មិន ព្រមស្តាប់ ។

បានឃើញសាលក្រមលេខ១៩៤ ចុះថ្ងៃទី ១៩_៧_៩៦ របស់តុលាការខេត្តបាត់ដំបង ដែល មានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

I_ក/ ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១២_១១_៩៥ របស់ដើមចោទឈ្មោះ ស្បៀក ចាន់ណារី ប្តឹង សុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជាកម្មសិទ្ធិ និងប្តឹងសុំឱ្យចុងចម្លើយឈ្មោះ ស៊ុម ញ៉ិក ដកដំណាំចេញពីដីទំនាស់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

ខ/ ទទួលសំណូមពររបស់ដើមចោទឈ្មោះ ស្បៀក ចាន់ណារី ប្តឹងសុំទាមទារសំណងអន្តរាយ លើផលដំណាំថ្មី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែបដិសេធចោលដោយផ្ទុយនិងគតិច្បាប់ ។

គ/ ទទួលសំណូមពររបស់ចុងចម្លើយឈ្មោះ ស៊ុម ញ៉ិក ប្តឹងសុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជា កម្មសិទ្ធិទុកជាត្រឹមត្រូវតាមច្បាប់និងទទួលសំណូមពររបស់ចុងចម្លើយប្តឹងសុំប្រគល់ដីទំនាស់មួយបាតផ្ទះឱ្យដើមចោទ ឈ្មោះ ស្បៀក ចាន់ណារី គ្រប់គ្រងជាកម្មសិទ្ធិទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនិង គតិច្បាប់ ។

II_ បែងចែកដីទំនាស់ស្ថិតនៅ ភូមិចំការសំរោង ១ ឃុំចំការសំរោង ស្រុកស្វាយប៉ោ ខេត្ត បាត់ដំបងជា២ភាគ និងប្រគល់ឱ្យដើមចោទឈ្មោះ ស្បៀក ចាន់ណារី និង ចុងចម្លើយឈ្មោះ ស៊ុម ញ៉ិក

គ្រប់គ្រងជាកម្មសិទ្ធិស្របច្បាប់ គិតចាប់ពីថ្ងៃដែលប្រកាសសាលក្រមនេះចូលជាស្ថាពរ ដោយគិតទំហំយកជាមូលដ្ឋាន តាមប្លង់បង្ហាញទីតាំងដីទំនាស់បណ្តឹងអាសន្ន ចុះថ្ងៃទី ១០_៤_៨៦ របស់ចៅក្រមផ្សះផ្សារសើុបអង្កេតគឺ :

ក_ ដើមចោទឈ្មោះសៀក ចាន់ណារី ផ្តល់ឱ្យទទួលភាគដីទំនាស់បែកខាងជើងក្នុងទំហំABFEA ( F ជាចំណុចបង្កើតថ្មីលើជ្រុង BC,E ជាចំណុចបង្កើតថ្មីលើជ្រុង DA ) មានប្រវែងជ្រុងនីមួយៗគឺ :

- ជ្រុង AB = 12,70m
- ជ្រុង BF = 17,40m
- ជ្រុង FE = 15,50m
- ជ្រុង EA = 19,20m

ខ_ ចុងចម្លើយឈ្មោះ ស៊ឹម ញ៉ិក ផ្តល់ឱ្យទទួលភាគដីទំនាស់បែកខាងត្បូងក្នុងទំហំ FCDEF (F ជាចំណុចបង្កើតថ្មីលើជ្រុង BC , E ជាចំណុចបង្កើតថ្មីលើជ្រុង DA ) មានប្រវែងជ្រុងនីមួយៗគឺ :

- ជ្រុង FC = 4,50m
- ជ្រុង CD = 16,50m
- ជ្រុង DE = 4,50m
- ជ្រុង EF = 15,50m

III_ ឱ្យដើមចោទឈ្មោះ សៀក ចាន់ណារី និងចុងចម្លើយឈ្មោះ ស៊ឹម ញ៉ិក គាស់រំលំចេញរៀងៗខ្លួន ចេញពីដីដែលបានបែងចែកផ្តល់ឱ្យកម្មសិទ្ធិចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

IV_ ឱ្យចុងចម្លើយឈ្មោះ ស៊ឹម ញ៉ិក បង់ប្រាក់ប្រដាប់ក្តីគឺ :

- ពន្ធចុះបញ្ជី និង ពន្ធហ្វ៊ីង : ១៨០០៛០០
- រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ : ២០០៛០០
- រង្វាន់ប្រគល់ដីកាកោះ : ២០០០៛០០
- ចំណាយកិច្ចស៊ើបសួរ : ៣០០០៛០០

ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចហើយ កាលបើហួសឧទ្ធរណ៍ឱ្យចុងចម្លើយសងប្រាក់ចំនួន ៧.០០០៛០០ ទៅដើមចោទវិញ និង ឱ្យចុងចម្លើយឈ្មោះ ស៊ឹម ញ៉ិក បង់ពន្ធសមាមាត្រចំនួន ២.០០០៛០០ និងឱ្យដើមចោទបង់ពន្ធសមាមាត្រចំនួន១.០០០៛០០ ប្រាក់នេះកាត់៨០% បង់ចូលថវិការដ្ឋ ២០% ដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមអនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី ២២_០៤_៨៩ តាមសេចក្តីណែនាំអនុវត្តលេខ ០៣ សណន ចុះថ្ងៃទី ០៣_៦_៨៩ តាមមាត្រា ៣ ,១៩ ,២០ ,៦១ ,៦២ ,៦៣ ,៦៥ ,៦៨ ,៧១ ៧៣ ,៧៤ ,៧៥ នៃច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី ១៣_១០_៩២ និង

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៧ក្រ.ចុះថ្ងៃទី ០៨_០២_៩៣ ។

V_ សាលក្រមនេះជំនុំជំរះប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវឧទ្ធរណ៍ ២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩៩ ចុះថ្ងៃទី ១៩_៨_៩៦ របស់លោក ស៊ឹម ញ៉ក ដែលប្តឹងជំទាស់នឹងសាលក្រមលេខ ១៩៤ ចុះថ្ងៃទី ១៩_៧_៩៦ របស់តុលាការខេត្តបាត់ដំបង លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាកំចាំងមុខរដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ស៊ឹម ញ៉ក ចុះថ្ងៃទី ១៩_៨_៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ តំកល់សាលក្រមរដ្ឋប្បវេណីលេខ១៩៤ ចុះថ្ងៃទី១៩_៧_៩៦ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្តី ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង អាជ្ញាធរតុលាការ ៥.០០០រៀល ។

៤_ សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះ សៀក ចាន់ណារី និង កំបាំងមុខឈ្មោះ ស៊ឹម ញ៉ក ។ បើកផ្លូវប្តឹងទាស់ និង ប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ១២_៥_៩៨ របស់លោក ស៊ឹម ញ៉ក បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១៧៣ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ ១៧៣ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ស៊ឹម ញ៉ក ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ខ្លួនមិនសុខចិត្តថាតុលាការខេត្ត និង សាលាឧទ្ធរណ៍ មិនយុត្តិធម៌

ទេ ដូចនេះខ្លួនប្ដឹងមកតុលាការកំពូលនេះ សុំជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ សៀក ចាន់ណារ៉ា ជាដើមចោទនិងជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ខ្លួនកាន់កាប់ដីនេះ តាំងពីឆ្នាំ១៩៧៩ មកដល់ឆ្នាំ ១៩៨៤ ឈ្មោះ ស៊ីម ញ៉ិក សំអាងថាដីតាំងពីដូនតាមក ពេលដែលខ្លួនធ្វើប្ដឹង គាត់មិនតវ៉ាអ្វីទាំងអស់ ដល់ឆ្នាំ១៩៩២ ទើបគាត់មកទំនាស់ ។ ខ្លួនសុំសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋានរបស់ខ្លួន ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ១២_៥_៩៨ របស់លោក ស៊ីម ញ៉ិក ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការកាន់កាប់ដីរបស់ដើមចោទ និង ចុងចម្លើយមានភាពច្របូកច្របល់គ្នា ហើយការដែលតុលាការថ្នាក់ក្រោមធ្វើការបែងចែកឱ្យដាច់ ដោយឡែកពីគ្នានោះជាការត្រឹមត្រូវហើយ។

- យល់ឃើញថា លោក ស៊ីម ញ៉ិក ម្ចាស់បណ្ដឹងសាទុក្ខ បានទទួលដីកាបង្គាប់ឱ្យធ្វើសារណាការពាររឿងក្ដីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែលោកពុំបានធ្វើសារណាជូនមកតុលាការកំពូល តាមការកំណត់ទេ ហើយការលើកឡើងរបស់លោកនាពេលសវនាការនេះ ថាលោកសុំឱ្យវាស់តាមបង្កាន់ដៃសុំកាន់កាប់ដីនោះ តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាឡើយ ហើយម្យ៉ាងទៀតការប្រកាសកាន់កាប់ដីពុំអាចកំណត់ពីទំហំដីដែលខ្លួនបានកាន់កាប់ឡើយគឺ ប្រកាសជាឯកតោភាគី ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី ៣០_៤_៩៨ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង អង្គច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១_ ទទួលបណ្ដឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ១២_៥_៩៨ របស់លោក ស៊ីម ញ៉ិក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងអង្គច្បាប់ ។

២_ តម្កល់សាលដីការដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី ៣០_៤_៩៨ របស់សាលាឧទ្ធរណ៍ទុក

ជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០ រៀល ដែលលោក ស៊ឹម ញ៉ិក បានបង់រួច ហើយគឺ ៖

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ីងចំនួន ៤.០០០រៀល ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់
- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។ បង្គាប់ឱ្យគូភាគីនៃរឿងក្ដីនេះ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តបាត់ដំបង។

៤_ សាលដីកានេះ ប្រកាសធាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១១_៥_៩៩ ។